ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
គម្រោង LASED III/IDA 6706-KH

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសក្រុមហ៊ុនប្រឹក្សាសម្រាប់ធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ ចំនួន ៣ តំបន់
## (Consulting Firm for Formulation of Commune Land Use Plans in 3 regions)

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ឱ្យបានជ្រាបថា គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី៣ (LASED III) កំពុងជ្រើសរើសក្រុមហ៊ុនប្រឹក្សាសម្រាប់ធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ ចំនួន ៣ តំបន់ (Consulting Firm for Formulation of Commune Land Use Plans in 3 regions)។

គោលបំណងអភិវឌ្ឍន៍គម្រោង គឺដើម្បីផ្តល់កម្មសិទ្ធិកាន់កាប់ដីធ្លី ការអភិវឌ្ឍកសិកម្ម សេវាសង្គម និងហេដ្ឋារចនាសម្ព័ន្ធសហគមន៍ និងលើកកម្ពស់ជីវភាពរស់នៅ ដល់កសិករខ្នាតតូច ដែលស្ថិតនៅក្នុងសហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជីដីសហគមន៍រួច និងដីសម្បទានសង្គមកិច្ចរបស់គម្រោង ក៏ដូចជាដើម្បីធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំនៅក្នុងប្រទេសកម្ពុជា។ គម្រោង LASED III បានទទួលហិរញ្ញប្បទានពីធនាគារពិភពលោក ដើម្បីគាំទ្រសកម្មភាពទាំងឡាយដែលរួមមាន ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រខ្នាតតូច ចំនួន ៧ ទីតាំង របស់គម្រោង LASED II និងផ្តល់ការអភិវឌ្ឍលើដីសម្បទានសង្គមកិច្ចចំនួន ១២ ទីតាំង, សហគមន៍ជនជាតិដើមភាគតិច ដែលបាន ចុះបញ្ជីដីសមូហភាពរួច ចំនួន ៣៣ សហគមន៍, ការរៀបចំចុះបញ្ជីដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ចំនួន ១៥សហគមន៍ និងការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ ចំនួន ៤៥០ឃុំ។

អាស្រ័យហេតុនេះ សូមក្រុមហ៊ុនប្រឹក្សា ដែលមានចំណាប់អារម្មណ៍លើការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ ទំនាក់ទំនងទៅគម្រោង LASED III ដើម្បីទទួលបានឯកសារតួនាទីនិងភារកិច្ច TORs សម្រាប់ធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ ចំនួន ៣ តំបន់ តាមរយៈលោក **ឫទ្ធី រតនៈជ័យសិទ្ធិ** នាយកប្រតិបត្តិការគម្រោង LASED III តាមរយៈអ៊ីម៉ែល rrcheyseth@yahoo.com ដោយចម្លងជូន tholdinajp@gmail.com និង ungnareth@yahoo.com ។

កាលបរិច្ឆេទផុតកំណត់នៃការដាក់ពាក្យ នៅថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០២១ ម៉ោង ១៧:៣០រសៀល។

ថ្ងៃព្រហស្បតិ៍ ២រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០២១